# មេរៀនទី ២៦៖ ព្រះអង្គគឺជាគំរូនៃសេចក្តីស្រឡាញ់

## ១ កូរិនថូស ១៣៖១-១៣

**មេរៀន** ( *យូធូបលីង* )៖ https://youtu.be/SibsKRoNUDM

**រឿងនៅក្នុងព្រះគម្ពីរសម្រាប់កុមារ៖** https://youtu.be/jSNNQN5siD0

**គោលបំណង៖** ព្រះអង្គគឺជាគំរូនៃសេចក្តីស្រឡាញ់

**ខគម្ពីរចងចាំ៖ យ៉ូហាន ១៣៖៣៤** *"ខ្ញុំឲ្យសេចក្តីបញ្ញត្ត១ថ្មីដល់អ្នករាល់គ្នា គឺឲ្យអ្នករាល់គ្នាស្រឡាញ់គ្នាទៅវិញទៅមក ត្រូវឲ្យស្រឡាញ់គ្នា ដូចជាខ្ញុំបានស្រឡាញ់អ្នករាល់គ្នាដែរ"។*

**ចំរៀង** ( *យូធូបលីង* )

១. ក្តីស្រលាញ់នៃព្រះផ្អែមហើយអស្ចារ្យ https://youtu.be/W7hfRd0undE

២. ព្រះយេស៊ូវស្រលាញ់កុមារណាស់ https://youtu.be/8iUI62Zo_Co

៣. ខ្ញុំឲ្យបញ្ញត្តិមួយថ្មី https://youtu.be/lio2oGzBFz8

**១. អធិស្ឋាន**

**២. ចំរៀង** ( *រើសចំរៀងខាងលើ១បទហើយច្រៀងជាមួយសិស្ស* )

**៣. ល្បែងកំសាន្ត** «ខ្ញុំស្រលាញ់...»

១. ឱ្យកុមារអង្គុយជារង្វង់។ (បើមានកៅអីសម្រាប់ឲ្យពួកគេអង្គុយកាន់តែប្រសើរ)

២. ជ្រើសរើសកុមារម្នាក់ធ្វើជាអ្នកដឹកនាំ ហើយឈរនៅកណ្តាលរង្វង់។



៣.កុមារនេះនឹងនិយាយថា "ខ្ញុំស្រឡាញ់ កុមារដែល_____" (ឧទាហរណ៍៖ "ខ្ញុំស្រឡាញ់កុមារដែលមានសក់វែង" ឬ "ខ្ញុំស្រឡាញ់កុមារដែលស្លៀកខោខ្លី" ឬ "ខ្ញុំស្រឡាញ់កុមារដែលពាក់វ៉ែនតា") កុមារណាដែលត្រូវនឹងការពិពណ៌នា ត្រូវតែក្រោកចេញពីកៅអី ហើយប្តូរទៅអង្គុយកន្លែងផ្សេងទៀត។ កុមារដែល ជាអ្នកដឹកនាំត្រូវអង្គុយយ៉ាងលឿននៅពេលកុមារណាម្នាក់ ក្រោកឡើង។

៤. កុមារណាដែលមិនអាចរកកៅអីថ្មីអង្គុយបាននឹងក្លាយជាអ្នកដឹកនាំបន្ទាប់ ហើយនិយាយថា "ខ្ញុំស្រឡាញ់កុមារដែល ____" ។

**៤. ការណែនាំមេរៀន**

តើប្អូនស្រឡាញ់អ្វីនៅក្នុងជីវិតរបស់ប្អូន? តើប្អូនស្រឡាញ់ម្ហូបអាហារដែរទេ? តើប្អូនស្រឡាញ់ប្រដាប់ក្មេងលេងទេ? តើប្អូនស្រឡាញ់អំណោយដែលគេឲ្យដែរទេ? នៅពេលប្អូនស្រលាញ់អ្វីមួយ ប្អូនចង់រក្សាវាឱ្យនៅជិតប្អូនជានិច្ច។ ឧទាហរណ៍៖ បើប្អូនស្រលាញ់របស់លេង នោះប្អូនចង់ទុករបស់លេងនោះនៅជិតប្អូន។ ឬបើប្អូនចូលចិត្តញ៉ាំអាហារ ប្អូនតែងតែចង់មានអាហារញ៉ាំជានិច្ច។ ឬប្រសិនបើប្អូនស្រឡាញ់នរណាម្នាក់ (ដូចជាម៉ាក់ឬប៉ារបស់ប្អូន) នោះ ប្អូនចង់ឱ្យពួកគេនៅក្បែរប្អូនរហូត។

ព្រះបានបង្កើតប្អូន ហើយទ្រង់ស្រឡាញ់ប្អូន។ ហើយដោយព្រោះព្រះស្រឡាញ់ប្អូន ស្រឡាញ់ខ្ញុំ ហើយនឹងអ្នកដទៃទៀតនោះហើយ ទើបព្រះអង្គចង់ឲ្យយើងនៅក្បែរទ្រង់។ វិធីមួយដែលបង្ហាញថា យើងមានទំនាក់ទំនងជិតស្និទ្ធនឹងព្រះគឺដោយការបង្ហាញសេចក្តីស្រឡាញ់របស់ព្រះចំពោះគ្នាទៅវិញទៅមក។

## ៥. រឿងនៅក្នុងព្រះគម្ពីរ

នៅក្នុងព្រះគម្ពីរមានជំពូកមួយដែលគេស្គាល់ថាជាជំពូកដែលនិយាយពីសេចក្តីស្រឡាញ់។ គឺនៅក្នុង **១ កូរិនថូស ១៣** ទាំងមូលនិយាយអំពីសេចក្តីស្រឡាញ់។ ខ ៤ និង ៥ ចែងថា "ឯសេចក្តីស្រឡាញ់ តែងតែអត់ធ្មត់ ហើយ ក៏សប្បុរស សេចក្តីស្រឡាញ់មិនចេះឈ្នានីស មិនចេះអួតខ្លួន ក៏មិនដែលមានចិត្តធំផង មិនដែលប្រព្រឹត្តបែបមិនគួរសម មិនដែលរកប្រយោជន៍ផ្ទាល់ខ្លួន មិនរហ័សខឹង មិនប្រកាន់ទោស" ។វ៉ូវ! សេចក្តីស្រឡាញ់គឺពិតជាអស្ចារ្យណាស់!

សេចក្តីស្រឡាញ់គឺសំខាន់ណាស់ចំពោះព្រះ។ ព្រះយេស៊ូវមានបន្ទូលថាសេចក្តីស្រឡាញ់ត្រូវតែសំខាន់សម្រាប់យើងរាល់គ្នាផងដែរ។ ព្រះយេស៊ូវមានព្រះបន្ទូលនៅក្នុង **យ៉ូហាន ១៣:៣៤** "ខ្ញុំឲ្យសេចក្តី បញ្ញត្តិ ១ថ្មីដល់អ្នក រាល់គ្នាគឺឲ្យអ្នករាល់គ្នាស្រឡាញ់គ្នាទៅវិញទៅមក ត្រូវឲ្យស្រឡាញ់គ្នា ដូចជាខ្ញុំបានស្រឡាញ់អ្នករាល់គ្នាដែរ" ។ វាមិនងាយស្រួលគ្រប់ពេលនោះទេ! ពេលខ្លះយើងត្រូវសុំព្រះយេស៊ូវឲ្យជួយយើងឲ្យស្រឡាញ់មនុស្សដែលយើងមិនចូលចិត្ត។ ខ្ញុំសប្បាយចិត្តណាស់ ដែលព្រះបានប្រទាននូវគម្ពីរដល់យើងដើម្បីជាជំនួយជួយយើងឲ្យចេះមានក្តីស្រឡាញ់។

ព្រះចង់ឲ្យយើងមករកទ្រង់ ដើម្បីទ្រង់អាចបំពេញយើងដោយសេចក្តីស្រឡាញ់របស់ទ្រង់។ បើទោះបីជាយើងបានធ្វើខុសក៏ដោយ យើងអាចទៅរកព្រះដើម្បីសុំការអភ័យទោស ហើយទទួលបាន នូវសេចក្តីស្រឡាញ់ពីទ្រង់បានដែរ។ ហេតុនេះហើយបានជាព្រះអង្គចាត់ព្រះរាជបុត្រាទ្រង់ឲ្យ មកសុគតជំនួសអំពើបាបរបស់យើង ហើយទ្រង់មានព្រះជន្មរស់ឡើងវិញ។ ព្រះយេស៊ូវស្រឡាញ់យើង ហើយបានសុគតសម្រាប់យើងរាល់គ្នា ដើម្បីឲ្យយើងបាននៅជាមួយទ្រង់ជារៀងរហូត។ នេះហើយជាក្តីស្រឡាញ់ដ៏ពិត! ព្រះបានបង្កើតក្តីស្រឡាញ់ពិត ព្រះស្រឡាញ់យើង ព្រះទ្រង់ជាតួនៃសេចក្តីស្រឡាញ់ ហើយព្រះចង់ឲ្យយើងស្រឡាញ់អ្នកដទៃផងដែរ។ ព្រះអង្គចង់ឲ្យអ្នកដទៃដឹងថា ទ្រង់ជាព្រះមានលក្ខណៈបែបណា តាមរយៈការស្រឡាញ់របស់យើងមានចំពោះពួកគេ។ ពេលយើងប្រព្រឹត្តដោយសេចក្តីស្រឡាញ់ គឺមានន័យថាយើងបានបំពេញបំណងព្រះហឫទ័យព្រះដែលស្រឡាញ់យើងដូច្នោះដែរ។

## ៦. សំនួរពិភាក្សា

១. តើជំពូកដែលនិយាយពីសេចក្តីស្រឡាញ់នៅក្នុងព្រះគម្ពីរមួយណា? *(១ កូរិនថូស ១៣)*

២. តើយើងអាចធ្វើអ្វីបាននៅពេលដែលយើងពិបាកក្នុងការស្រឡាញ់នរណាម្នាក់?
*(សូមព្រះយេស៊ូវជួយយើងឲ្យស្រឡាញ់មនុស្សនោះ)*

៣. តើព្រះបានបង្ហាញសេចក្តីស្រឡាញ់ពិតរបស់ព្រះអង្គចំពោះយើងដោយរបៀបណា?
*(ទ្រង់បានចាត់ព្រះយេស៊ូវជាបុត្ររបស់ទ្រង់ឲ្យសុគតដោយព្រោះអំពើបាបរបស់យើង ហើយទ្រង់រស់ឡើងវិញ ដើម្បីឲ្យយើងបាននៅជាមួយនឹងទ្រង់ជារៀងរហូត)*

៤. តើយើងគួរធ្វើអ្វីក្នុងនាមជាមនុស្សទទួលបានក្តីស្រឡាញ់ពីព្រះជាម្ចាស់?
*(យើងត្រូវស្រឡាញ់ព្រះ និងស្រឡាញ់អ្នកដ៏ទៃដែរ!)*

## ៧. ល្បែងកំសាន្ត «តើអ្វីជាសេចក្តីស្រឡាញ់?»

សម្ភារដែលត្រូវការ៖ ខ្មៅដៃ និងបោះពុម្ពព្រះគម្ពីរ **១កូរិនថូស ១៣៖៤-៧** (សូមមើលខាងក្រោម)

១.ឲ្យកុមារចាប់ដៃគូ ២នាក់ៗ សូមឲ្យក្រដាសថតចំលង **១ កូរិនថូស ១៣៖៤-៧** ១ច្បាប់ឲ្យក្រុមនីមួយៗ។

**សូមគូសរង្វង់ពាក្យដែលពណ៌នាអំពីក្ដីស្រឡាញ់៖**
**១ កូរិនថូស ១៣៖៤-៧**
៤ ឯសេចក្ដីស្រឡាញ់តែងតែអត់ធ្មត់ ហើយក៏សប្បុរស សេចក្ដីស្រឡាញ់មិន ចេះឈ្នានីស មិនចេះអួតខ្លួន ក៏មិនដែលមានចិត្តធំផង
៥ មិនដែលប្រព្រឹត្តបែបមិនគួរសម មិនដែលរកប្រយោជន៍ផ្ទាល់ខ្លួន មិនរហ័សខឹង មិនប្រកាន់ទោស
៦ មិនដែលអរសប្បាយចំពោះសេចក្ដី ទុច្ចរិតឡើយ គឺអរសប្បាយតែនឹងសេចក្ដី ស្មោះត្រង់វិញ
៧ ក៏គ្របបាំងទាំងអស់ ជឿទាំងអស់ សង្ឃឹមទាំងអស់ ហើយទ្រាំទ្រទាំងអស់

២. ឲ្យពួកគេគូសរង្វង់ពាក្យទាំងអស់ដែលនិយាយអំពីសេចក្ដីស្រឡាញ់។

៣.ប្រហែល ៥នាទីក្រោយមក សូមឱ្យកុមារបំពេញនូវអ្វីដែលគ្រូនិយាយ(គ្រូនឹងជ្រើសរើសក្រុមដែលលើកដៃមុនគេ។ ក្រុមដែលឆ្លើយបានមុនគេនឹងទទួលបានពិន្ទុ)៖

ក. ៤.សេចក្ដីស្រឡាញ់គឺ _________ (អត់ធ្មត់) សេចក្ដីស្រឡាញ់គឺ ________ (សប្បុរស) ។ មិនចេះ ________ (ឈ្នានីស) មិនចេះ _______ (អួតខ្លួន) មិនដែល _______ (មានចិត្តធំ) ។ ៥. មិនចេះ __________ (ប្រព្រឹត្តបែបមិនគួរសមនឹងអ្នកដ៏ទៃ) មិនរក________ (ប្រយោជន៍ផ្ទាល់ខ្លួន) មិន __________ (រហ័សខឹង) មិន ________ (ប្រកាន់ទោស) ។ ៦. សេចក្ដីស្រឡាញ់មិន ________ (អរសប្បាយចំពោះសេចក្ដីទុច្ចរិតឡើយ) ប៉ុន្តែអរសប្បាយជាមួយនឹង _________ (សេចក្ដីស្មោះត្រង់វិញ) ។ ៧. តែងតែ ________ (គ្របបាំងទាំងអស់) តែងតែ _________ (ជឿទាំងអស់) តែងតែ ________ (សង្ឃឹមទាំងអស់) តែងតែ _________ (ទ្រាំទ្រទាំងអស់) ។

៤. សួរកុមារថាតើពាក្យដែលពណ៌នាអំពីសេចក្ដីស្រឡាញ់មួយណាដែលពួកគេចូលចិត្ត ហើយឲ្យពួកគេពន្យល់ថាហេតុអ្វីបានជាគេចូលចិត្តពាក្យនោះ។

### ៨. ខគម្ពីរចងចាំ

**យ៉ូហាន ១៣៖៣៤** *"ខ្ញុំឲ្យសេចក្ដីបញ្ញត្តិ១ថ្មីដល់អ្នករាល់គ្នា គឺឲ្យអ្នករាល់គ្នាស្រឡាញ់គ្នា ទៅវិញទៅមក ត្រូវឲ្យស្រឡាញ់គ្នា ដូចជាខ្ញុំបានស្រឡាញ់អ្នករាល់គ្នាដែរ"។*

### ៩. ហត្ថកម្ម

សម្ភារៈដែលត្រូវការ៖ បោះពុម្ព "ផ្កានៃក្ដីស្រឡាញ់" (សូមមើលខាងក្រោម) ខ្មៅដៃពណ៌



១. ឲ្យ "ផ្កានៃក្ដីស្រឡាញ់" ដល់កុមារម្នាក់ៗ។

២.ឲ្យកុមារសរសេរពីការពណ៌នាអំពីសេចក្ដីស្រឡាញ់ពី **១ កូរិនថូស ១៣** (ប្រើច្បាប់ចម្លងដែលបានប្រើក្នុងល្បែង) លើត្របកផ្កា រួចលាបពណ៌ដើម្បីតុបតែង

៣.ពន្យល់ដល់កុមារថាយើងត្រូវតែស្រឡាញ់អ្នកដទៃដោយសារព្រះអង្គទ្រង់ស្រឡាញ់យើង។

### ១០. ចំរៀង *(រើសចំរៀងខាងលើ១បទហើយច្រៀងជាមួយសិស្ស)*

### ១១. អធិស្ឋាន

**ការថ្វាយបង្គំសំរាប់គ្រូ៖ (សូមអាន ហើយអធិស្ឋានមុនពេលចាប់ផ្ដើមបង្រៀន)**
សូមអាន **កូរិនថូស ទី ១៖១៣** ម្ដងទៀត ហើយសរសេរអំពីរបៀបដែលប៉ុលបានពិពណ៌នាអំពីសេចក្ដីស្រឡាញ់។ គូសរង្វង់ពាក្យដែលអ្នកគិតថា វាពិពណ៌នាអំពីគុណភាពនៃសេចក្ដីស្រឡាញ់របស់អ្នក។ ដាក់ផ្កាយមួយនៅជាប់នឹងលក្ខណៈណាមួយ ដែលអ្នកចង់បានជំនួយពីព្រះយេស៊ូវ ដើម្បីអភិវឌ្ឍនៅក្នុងជីវិតរបស់អ្នក។ តើជីវិតរបស់អ្នកអាចប្រែប្រួលយ៉ាងណា ប្រសិនបើអ្នកអាចស្រឡាញ់ដោយគ្រប់លក្ខណ៍? តើជីវិតអ្នកដ៏ទៃនឹងផ្លាស់ប្ដូរយ៉ាងដូចម្ដេច? ចូរអធិស្ឋាន ហើយសុំព្រះយេស៊ូវ ដើម្បីកែលម្អគុណភាពនៃសេចក្ដីស្រឡាញ់របស់អ្នក ។

**សូមគូសរង្វង់ពាក្យដែលពណ៌នាអំពីក្តីស្រឡាញ់៖**

**១ កូរិនថូស ១៣៖៤-៧**

៤ ឯសេចក្ដីស្រឡាញ់តែងតែអត់ធ្មត់ ហើយក៏សប្បុ
រស សេចក្ដីស្រឡាញ់មិន ចេះឈ្នានីស មិនចេះអួត
ខ្លួន ក៏មិនដែលមានចិត្តធំផង
៥ មិនដែលប្រព្រឹត្តបែបមិនគួរសម មិនដែលរកប្រ
យោជន៍ផ្ទាល់ខ្លួន មិនរហ័សខឹង មិនប្រកាន់ទោស
៦ មិនដែលអរសប្បាយចំពោះសេចក្ដី ទុច្ចរិតឡើយ
គឺអរសប្បាយតែនឹងសេចក្ដី ស្មោះត្រង់វិញ
៧ ក៏គ្របបាំងទាំងអស់ ជឿទាំងអស់ សង្ឃឹមទាំង
អស់ ហើយទ្រាំទ្រទាំងអស់

# “ផ្កានៃក្តីស្រឡាញ់”

